More than just a job

# អ្វីៗក៏អាចទៅរួច

## លើសពីការងារទៅទៀត

**Jobfind គឺជាសេវាជួយរកការងារមួយដែលបំពេញមុខនាទីដ៏ប្រសើរបំផុត ក្នុងការផ្តល់កិច្ចបំរើដល់ អ្នកសកម្មរកការងារ ( Jobactive ) និងសេវាការងារសម្រាប់អ្នកមានពិការភាព (Disability Employment Services) ។**

បទពិសោធន៍២០ឆ្នាំរបស់យើងធ្វើឱយយើងក្លាយជាជម្រើសដ៏ល្អបំផុតសម្រាប់ជួយលោកអ្នកក្នុងការ រកការងារធ្វើនិងរក្សាការងារឱយបាន។

ចាប់តាំងពីឆ្នាំ១៩៩៨មក **Jobfind** បានជួយប្រជាពលរដ្ឋឱយមានសមត្ថភាពក្លាយជាមនុស្សឯករាជ្យលើ ហិរញ្ញកិច្ច និងធ្វើឱយស្ថានភាពជីវភាពរបស់ពួកគាត់កាន់តែប្រសើរឡើង។

កំរិតផ្កាយប្រាំរបស់ភ្នាក់ងារជួយរកការងារ ក្នុងការផ្តល់ជូននូវដំណោះស្រាយកម្លាំងការងារ នោះគឺជាអ្វី ដែលប្លែកពីគេ។

យើងផ្តល់ជូនកិច្ចបំរើដល់ អ្នកសកម្មរកការងារ (Jobactive) និងសេវាការងារសម្រាប់អ្នកមានពិការភាព

### សូមផ្លាស់ប្តូរជីវិតលោកអ្នកក្នុងថ្ងៃនេះ!

លោកអ្នកជាអ្នកគ្រប់គ្រងសភាពការណ៍។ សូមជ្រើសរើសភ្នាក់ងារជួយរកការងារឱយបានត្រឹមត្រូវ សម្រាប់លោកអ្នក។

ប្រសិនបើលោកអ្នកចង់ឱយគេប្រព្រឹត្តមកលើលោកអ្នកថាជាមនុស្ស ពុំមែនជាតួរលេខនោះ ហើយចង់ ឱយដំណើររកការងារធ្វើប្រកបដោយភាពរីករាយ សូមទាក់ទងមក **Jobfind** ក្នុងថ្ងៃនេះ។

## ការសន្យារបស់យើងចំពោះលោកអ្នក៖

- យើងនិយាយភាសារបស់លោកអ្នក ហើយផ្តល់ជូននូវសេវាបកប្រែទៀតផង។
- យើងនឹងស្តាប់លោកអ្នកពេលដែលអ្នកដទៃមិនស្តាប់ឬមិនបានស្តាប់សម្តីលោកអ្នក។
- យើងនឹងធ្វើគម្រោងជាមួយលោកអ្នកដើម្បីសម្រេចគោលបំណងរបស់លោកអ្នក។
- យើងនឹងជួបលោកអ្នកទៅតាមតម្រូវការនៅពេលមានភាពងាយស្រួលចំពោះលោកអ្នក។
- យើងមានបទពិសោធន៍ជាង២០ឆ្នាំក្នុងការជួយពលរដ្ឋដូចជាលោកអ្នក។
- យើងមានទំនាក់ទំនងជិតដិតជាមួយនិយោជកដែលមានការងារក្នុងតំបន់។
- យើងបានជួយរកការងារឱយប្រជាពលរដ្ឋអូស្ត្រាលីធ្វើជាងកន្លះលាននាក់។

## សេវារបស់យើង៖

- ការងារទំនេរក្នុងមូលដ្ឋានជាច្រើនប្រភេទយ៉ាងទូលំទូលាយ។
- ប្រើប្រាស់បច្ចេកវិទ្យាថ្មីដើម្បីជួយក្នុងសកម្មភាពរកការងារ។
- យកចិត្តទុកដាក់និងជ្រោមជ្រែងពិតប្រាកដពីបុគ្គលឹកប៉ិនប្រសប់និងមានបទពិសោធន៍ដើម្បីជួយលោក អ្នកកសាងផ្លូវឆ្ពោះទៅរកការងារដែលមានអត្ថន័យ។
- ជួយរៀបចំប្រវត្តិរូបសង្ខេបនិងបង្ហាត់បង្រៀនលោកអ្នកឱយមានចំណេះដឹង ការជឿជាក់ និងជំនាញសម្រាប់បទសម្ភាសន៍។
- ប្រើប្រាស់កម្មវិធីដើម្បីកំណត់សម្គាល់ភាពខ្លាំងរបស់លោកអ្នក និងការងារដែលត្រឹមត្រូវសម្រាប់លោកអ្នក។
- ប្រើប្រាស់កម្មវិធីហ្វឹកហាត់នានាជាច្រើនដែលទទួលបានពានរង្វាន់។
- បទពិសោធន៍ជាមួយអ្នកប្រកបអាជីវកម្មក្នុងតំបន់ ដើម្បីជួយលោកអ្នកឱយមានជំនាញលើការងារ។
- ទំនាក់ទំនងជិតស្និទ្ធជាមួយនិយោជកក្នុងតំបន់ដែលរង់ចាំបេក្ខជនត្រឹមត្រូវសម្រាប់ការងារ។
- ទំនាក់ទំនងនិងផ្តល់ការជ្រោមជ្រែងយ៉ាងទៀតទាត់ពេលលោកអ្នកទទួលបានការងារក្នុងសុបិនរបស់លោកអ្នក។

## តើលោកអ្នកមានពិការភាព ជំងឺដង្កាត់ ឬរងរបួសហើយកំពុងស្វែងរកការងារធ្វើ ?

សូមសួរនាំយើងខ្ញុំអំពីសេវាកម្មការងារសម្រាប់ជនមានពិការភាពនៅទីក្រុង ស៊ីដនី មែលប៊ន វ៉ូឡុងហ្គុង និងទីក្រុងខេនស៍។

យើងបានជ្រោមជ្រែងប្រជាពលរដ្ឋដែលមានពិការភាពជាច្រើនឆ្នាំមក ហើយ រួមទាំងអ្នកដែលមានប្រវត្តិជាតិ សាសន៍និង វប្បធម៌ផ្សេងៗគ្នា។

យើងក៏ផ្តល់ជូនផងដែរនូវកម្មវិធីជំនួយអន្តរកាលសម្រាប់ការងារ (Career Transition Assistance Program) បន្ទាប់ពីមាតាបិតា (ParentsNext) និងកម្មវិធីជាតិសម្រាប់ការធានារ៉ាប់រងពិការភាព (NDIS) នៅក្នុងតំបន់ផ្សេងៗជាច្រើនក្នុងទីក្រុងមែលប៊ន។

**P: ១៨០០ ១១៣២៣៣ E: team@jobfindcentre.com.au www.jobfind.com.au**